# របាយការណ៍ប្រចាំខែវិច្ឆិកា ឆ្នាំ ២០១៤ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **ស្ថានភាពមន្ត្រីរាជការ**÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣១ នាក់ ស្ត្រី ០៤ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. **សកម្មភាពថ្នាក់ដឹកនាំមន្ទីរ**÷

- ចូលរួមក្នុងពិធីសំណេះសំណាល ស្តីពី ការចុះពិនិត្យមើលលទ្ធផលនៃការបោសសម្អាតមីន ប្រចាំឆ្នាំ២០១៤ នៅថ្ងៃទី៣១/១០/២០១៤ ភូមិច្រវ៉ា ឃុំកន្ទួត ស្រុកចិត្របុរី
- ចូលរួមក្នុងពិធីបើកបវេសនកាលឆ្នាំ២០១៤-២០១៥ នៅថ្ងៃទី ០៤/១១/២០១៤ នៅវិទ្យាល័យព្រះ មហាក្សត្រីយានីកុសុមៈ
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារលើគ្រប់វិស័យ ប្រចាំខែតុលាឆ្នាំ២០១៤ នៅថ្ងៃទី១០/១១/២០១៤ នៅ សាលប្រជុំសាលាខេត្ត
- ចូលរួមពិធីបុណ្យឯករាជ្យជាតិ៩ វិច្ឆិកា និងទិវាកំណើតកងយោធពលខេមរភូមិន្ទ នៅថ្ងៃទី១២/១១/២០១៤ នៅសាលមហោស្រពខេត្ត
- ចូលរួមប្រជុំសាមញ្ញលើកទី៤ អាណត្តិទី២ ឆ្នាំទី១ របស់ក្រុមប្រឹក្សាខេត្ត នៅថ្ងៃទី១៨/១១/២០១៤ នៅ សាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមវេទិកាសាធារណៈ ជួបជាមួយប្រជាពលរដ្ឋនៅភូមិថ្មី ឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ថ្ងៃទី១៩/១១/២០១៤ ។

3. **សកម្មភាពតាមការិយាល័យ**÷

3.1. **ការិយាល័យរដ្ឋបាល និងបុគ្គលិក**÷

ក. <u>ផ្នែកការងារលិខិតចូល</u> ÷ សរុបចំនួន ៤៧ លេខ ក្នុងនោះមានៈ

- លិខិតរបស់រាជរដ្ឋាភិបាល ចំនួន ០៣ លេខ
- លិខិតរបស់ក្រសួងសាមី ចំនួន ០៧ លេខ
- លិខិតក្រសួងនានា ចំនួន ០៥ លេខ
- លិខិតផ្សេងៗក្នុងខេត្ត ចំនួន ៣២ លេខ ។

ខ. <u>ផ្នែកការងារលិខិតចេញ</u>÷ សរុបចំនួន ៦៤ លេខ ក្នុងនោះមានៈ

- លិខិតទៅនាយកដ្ឋាន និងក្រសួង សាមី ចំនួន ៣៤ លេខ
- លិខិតផ្សេងៗទូទៅ ក្នុងខេត្ត ចំនួន ៣០ លេខ ។

គ. <u>ផ្នែកការងារលិខិតបញ្ជាបេសកកម្ម</u>÷ សរុបចំនួន ២៤ លេខ

- ធ្វើសំណើសុំលិខិតបញ្ជាបេសកកម្មលោកប្រធានមន្ទីរ ពី **ឯកឧត្តមអភិបាលខេត្ត** ចំនួន០២ លេខ
- ចេញលិខិតបញ្ជាបេសកកម្មជូនមន្ត្រីចំនួន ២២ លេខ ។

ឃ. ផ្នែកបញ្ជីវត្ថុមាន÷ ពិនិត្យការចុះបញ្ជីវត្ថុមានជាប្រចាំថ្ងៃ ។

3.2. **ការិយាល័យផ្លូវលំជនបទ÷**

3.2.1. **លទ្ធផលការងារ÷**

- ការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួប ភូមិអូរព្រះ ទៅភូមិខ្សាច់លាវ ឃុំអូរគ្រៀង ស្រុកសំបូរ ប្រវែង ១០.០០០ ម៉ែត្រ សម្រេចលទ្ធផលបាន ១០០% ។
- ការងារជួសជុលថែទាំផ្លូវ ភូមិឈ្នៃទៅភូមិស្រែទ្រៀក ឃុំឆ្លូង និងឃុំដំរីផុង ស្រុកឆ្លូង ប្រវែង ១៩.២០០ ម៉ែត្រ លទ្ធផលសម្រេចបាន ១០០% ។

3.2.2. **សកម្មភាពការិយាល័យ÷**

- ចុះទៅពិនិត្យការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួបភូមិអូរព្រះទៅភូមិខ្សាច់លាវ ឃុំអូរគ្រៀង ស្រុកសំបូរ ប្រវែង ១០.០០០ ម៉ែត្រ បានចំនួន ៣ លើក ។
- ចុះទៅពិនិត្យការងារជួសជុលថែទាំផ្លូវ ភូមិឈ្នៃទៅភូមិស្រែទ្រៀក ឃុំឆ្លូង និងឃុំដំរីផុង ស្រុកឆ្លូង ប្រវែង ១៩.២០០ បានចំនួន ៤ លើក ។
- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួង មានក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ចុះពិនិត្យ និងវាយតម្លៃ ប្រគលទទួលបញ្ចប់ការងារជួសជុលថែទាំជាលក្ខណៈខួប ១០០% ផ្លូវភូមិអូរព្រះទៅភូមិខ្សាច់លាវ ប្រវែង ១០.០០០ ម៉ែត្រ ស្ថិតនៅឃុំអូរគ្រៀង ស្រុកសំបូរបាន ១ លើក ។

3.3. **ការិយាល័យផ្គត់ផ្គង់ទឹកជនបទ÷**

- ចុះជួសជុលអណ្តូងស្នប់ខូចបានចំនួន ០៦ អណ្តូង÷
  - ស្រុកចិត្របុរី ចំនួន ០៤ អណ្តូង ស្ថិតនៅឃុំដារ ភូមិតាងួន ០២ អណ្តូង និងឃុំបុសលាវ ភូមិព្រែកក្ងូរ ០២ អណ្តូង ។
  - ស្រុកព្រែកប្រសព្វ ឃុំតាម៉ៅ ភូមិខ្សាត់ ០២ អណ្តូង (កាកបាទក្រហម) ។

3.4. **ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ÷**

- សហការជាមួយអង្គការ (PYD) ចូលរួមប្រជុំឥណទានលុយជាមួយប្រជាជន ១៦ នាក់ ស្ត្រី ៦ នាក់ ឃុំកោះច្រែង ចំនួន ៧៣.០០.០០០ រៀល សំរាប់ធ្វើស្រែ ចិញ្ចឹមមាន់ ចិញ្ចឹមជ្រូក និងដាំដំឡូង ។

3.5. **ការិយាល័យអភិវឌ្ឍន៍សហគមន៍÷**

- បានចុះទៅបណ្តុះបណ្តាល គ.អ.ភ ស្តីពីការធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ បានចំនួន ០៦ វគ្គ នៅក្នុងស្រុកសំបូរ ស្មើនឹង ០៦ ឃុំ ស្មើនឹង ៤២ ភូមិ និងមានអ្នកចូលរួមចំនួន ២១០ នាក់ ក្នុងនោះស្ត្រីមាន ចំនួន ៦៣ នាក់ ។

- ចូលរួមប្រជុំ ស្តីពី ការធ្វើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សហគមន៍ (ឆ្នាំ២០១៤-២០១៨) នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។
- ចុះបណ្តុះបណ្តាល គ.អ.ភ ស្តីពី គោលគំនិតនៃការអភិវឌ្ឍសហគមន៍ ក្រោមកិច្ចសហការរវាងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ និងអង្គការឆាលហ្វានកម្ពុជាប្រចាំខេត្តក្រចេះ បានចំនួន ៤ វគ្គ ស្មើនឹង ០៣ ឃុំ ស្មើនឹង ១៧ ភូមិ និងមាន គ.អ.ភ ចូលរួមចំនួន ១១៤ នាក់ ក្នុងនោះស្ត្រីមានចំនួន ៥១ នាក់ ។

3.6. <u>**ការិយាល័យជនជាតិដើមភាគតិច÷**</u> (គ្មានសកម្មភាព)

3.7. <u>**ការិយាល័យថែទាំសុខភាពជនបទ÷**</u>

- ចុះផ្សព្វផ្សាយ និងបំផុសឲ្យប្រជាជនស្ម័គ្រចិត្ត សាងសង់បង្គន់ដោយខ្លួនឯង ក្នុងស្រុកឆ្លូងបានចំនួន ៦០ បង្គន់ ។
- ផ្តល់សំភារៈសាងសង់បង្គន់ចំនួន ៣០ គ្រួសារ នៅឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ។
- ផ្សព្វផ្សាយស្តីពីការលើកកម្ពស់អនាម័យសហគមន៍ជនបទក្នុងស្រុកព្រែកប្រសព្វមាន÷
  - ឃុំជ្រោយបន្ទាយ មានអ្នកចូលរួម ៧៦ នាក់ ស្ត្រី ៥១ នាក់
  - ឃុំវឌ្ឍនៈ មានអ្នកចូល ១០៩ នាក់ ៧៩ នាក់ ។
- កម្មវិធីទិវាជាតិលើកកម្ពស់អនាម័យជនបទ ១៣ វិច្ឆិកា ឆ្នាំ២០១៤ ក្រោមប្រធានបទ វិនិយោគអនាម័យដើម្បីកូនចៅជំនន់ក្រោយ នៅសាលាបឋមសិក្សាភូមិក្រូច ឃុំដីរីជុង ស្រុកឆ្លូង មានអ្នកចូលរួមចំនួន ៣៦០ នាក់ ស្ត្រី ១៧២ នាក់ ។

3.8. <u>**ការងារបណ្តុះបណ្តាលមន្ត្រីរាជការ÷**</u>

- លោក សុខ ស៊ីថា ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក លោក អ៊ុត អុល ប្រធានការិយាល័យផែនការ និងស្ថិតិ លោក ផេង ស៊ីណិត មន្ត្រីការិយាល័យរដ្ឋបាល និងបុគ្គលិក និងធុន បូនិត (ស្រី) មន្ត្រីការិយាល័យគណនេយ្យ ហិរញ្ញវត្ថុ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងអនុវត្តការរៀបចំផែនការ និងគ្រប់គ្រងធនធានមនុស្ស ចាប់ពីថ្ងៃទី ១៧ ដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅសណ្ឋាគារ លីជី ក្រោមការឧបត្ថម្ភដោយសាលាខេត្តក្រចេះ ។
- លោក លឹម ជាវហាវ ប្រធានមន្ទីរ លោក ម៉ៅ សុខជា អនុប្រធានមន្ទីរ លោក សោម ជួន អនុប្រធានការិយាល័យបណ្តុះបណ្តាល បានចូលរួមសិក្ខាសាលា បូកសរុបលទ្ធផលស្តីពីការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍន៍ធនធានមនុស្ស កាលពីថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ ក្រោមការឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោក លឹម ជាវហាវ ប្រធានមន្ទីរ លោក មាន គីមតេង អនុប្រធានការិយាល័យជនជាតិដើមភាគតិច បានចូលរួមសិក្ខាសាលាការផ្សព្វផ្សាយការអនុវត្តយន្តការអន្តរក្រសួងលើ ការពង្រឹងការគ្រប់គ្រងសប្បទានដីសេដ្ឋកិច្ច កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅសណ្ឋាគារ រតនៈស៊ីធី ក្រោមការឧបត្ថម្ភដោយអង្គការ NGOs forum ។

4. **<u>ទិសដៅបន្ត÷</u>**

- ចុះស្រង់ទិន្នន័យផ្លូវតាមប្រព័ន្ធ GPS ក្នុងស្រុកចិត្របុរី និងស្រុកសំបូរ ដើម្បីរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវ និងផែនទីក្នុងខេត្តក្រចេះ ។
- ចុះជួសជុលបន្ទាន់ផ្លូវរងការខូចខាតដោយទឹកជំនន់ឆ្នាំ២០១៤ ប្រវែង២.១០០ ម៉ែត្រ ស្ថិតនៅឃុំថ្មអណ្តើក ស្រុកចិត្របុរី ។
- បន្តវគ្គបណ្តុះបណ្តាល គ.អ.ភ ចំនួន ២ វគ្គ ទៀត នៅក្នុងស្រុកឆ្លូង ដែលជាភូមិគោលដៅរបស់អង្គការ ឆាលហ្វានកម្ពុជាប្រចាំខេត្តក្រចេះ ។
- ចុះស្រង់ពត៌មានអណ្តូងស្នប់ខូច ស្រុកស្នួល ។
- ផ្សព្វផ្សាយ និងតាមដានការសាងសង់បង្គន់ចាក់ទឹក នៅឃុំព្រែកសាម៉ាន់ ឃុំកញ្ជរ ស្រុកឆ្លូង, ឃុំសណ្តាន់ ឃុំសំបូរ ស្រុកសំបូរ, ឃុំថ្មគ្រែ ឃុំគោលាប់ ឃុំបុសលាវ ឃុំសំបុក ស្រុកចិត្របុរី និងឃុំសោប ឃុំព្រែកប្រសព្វ ឃុំចំបក់ ឃុំឬស្សីកែវ ឃុំវឌ្ឍនៈ ស្រុកព្រែកប្រសព្វ ។

**ប្រធានមន្ទីរ**